# ការសំភាសន៍របស់លោកតា ហាន ហេង

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ រ៉េន សារិន ខៈអ្នកត្រូវគេសំភាសន៍ឈ្មោះ ហាន ហេង

កៈ នាងខ្ញុំសូមថ្លែងអំណរគុណដល់តា ដែលបានផ្តល់ឪកាសនាងខ្ញុំធ្វើការសំភាសន៍មកដល់តា។ ហើយការសំភាសន៍នេះត្រូវបានធ្វើឡើង នូវសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិច មានឈ្មោះថា BYU ។ ដែលសាកលវិទ្យាល័យមាន គោលបំណងចង់រក្សាប្រវត្តិប្រជាជនខ្មែរ ដើម្បីកូនចៅជំនាន់ក្រោយអាចបានស្គាល់អំពីប្រវត្តិលោកតា។ ហើយនៅពេលដែលខ្ញុំសំភាសន៍តា ខ្ញុំហ្នឹងដាក់សំលេងរបស់លោកតា ទៅក្នុងវេបសាយរបស់សាលា មានឈ្មោះថា www.cambodiaoralhistory.byu.edu ។ ហើយនៅថ្ងៃខែដែលខ្ញុំសំភាសន៍លោកតា នៅថ្ងៃទី៣០ ខែ៣ ឆ្នាំ២០១៧ ហើយនៅភូមិព្រែកស្វាយ ឃុំឬស្សី ស្រុករាំងកេរសី ខេត្តបាត់ដំបងណាតា។ ហើយខ្ញុំជាអ្នកសំភាសន៍ហ្នឹងមានឈ្មោះថា រ៉េន សារិន ខ្ញុំចង់សួរថាឈ្មោះពេញរបស់តាមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំមានឈ្មោះ ហាន ហេង។

កៈ តើលោកតាមានឈ្មោះហៅក្រៅទៀតទេ? ដូចជានៅពីតូចមានអ្នកណាហៅឈ្មោះផ្សេងទេ?

ខៈ អត់មានទេ ខ្ញុំមានឈ្មោះតែមួយហ្នឹង។

កៈ លោកតាមាននៅចាំឆ្នាំកំនើតទេ?

ខៈ ខ្ញុំកើតនៅឆ្នាំឆ្លូវ។

កៈ ឆ្នាំឆ្លូវ ត្រូវជាសត្វអ្វីដែរ?

ខៈ ឆ្នាំឆ្លូវត្រូវជាសត្វគោ។

កៈ ចឹង លោកតាមានចាំថា តើលោកតាបានកើតនៅថ្ងៃខែឆ្នាំណាដែរ? ត្រូវជាឆ្នាំបារាំងណា?

ខៈ ដូចជានៅឆ្នាំ ១៩៤៩ បើសិនជាថ្ងៃនឹងខែ គឺខ្ញុំអត់បានចាំទេ។

កៈ ចុះតា មានដឹងថាលោកតាមានទីកន្លែងកំនើតនៅណាទេ?

ខៈ កើតនៅទូលក្របី នៅក្របីដងទង់។

កៈ ចាស! នៅភូមិអ្វី ស្រុកអ្វីដែរ?

ខៈ នៅឃុំកំពិល ពីដើមមិនដឹងជាឃុំអីទេ តែដល់ពេលខ្ញុំកើត គេហៅឃុំកំពិល ស្រុកបាណន់។

កៈ ភូមិអីគេដែរតា?

ខៈ ភូមិខ្ទង់របើក ពីដើមមិនសូវមានភូមិអីច្រើនទេ ពីដើមមានមនុស្សរស់នៅតែប៉ុន្មាននាក់ទេ។

កៈ ចុះលោកតា មានបងប្អូនចំនួនប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំមានបងប្អូនតែ២នាក់ទេ។

កៈ លោកតាត្រូវជាកូនទីប៉ុន្មានដែរ នៅក្នុងក្រុមគ្រួសារ?

ខៈ ខ្ញុំជាកូនពៅគេ។

កៈ ចាស! តើលោកតាអាចជួយប្រាប់បងប្អូនរបស់តាបានទេ ពួកគាត់មានឈ្មោះអ្វីដែរ?

ខៈ មានឈ្មោះ ហ៊ុន។

កៈ តើលោកតាមានចាំសាច់រឿងអ្វីខ្លះអំពីពួកគាត់
ដូចជាតាមានអនុស្សាវរីយ៍អីគេខ្លះជាមួយបងប្អូនលោកតា?

ខៈ ពីដើមមកបងប្អូន២នាក់ហ្នឹង ខិតខំសិក្សារៀនសូត្រ រហូតដល់អាយុ១៨ឆ្នាំទើបចេញទៅបួស។
ចេញទៅបួសរហូតដល់អាយុ២១ឆ្នាំ ទើបខ្ញុំសឹកលាចាកសិក្ខាបទមកវិញ
អាយុ២២ឆ្នាំទើបបានរៀបការប្រពន្ធ នៅឆ្នាំ១៩៧២ហ្នឹងឯង។ រហូតមកដល់ឆ្នាំ១៩៧៥
របបប៉ុលពតក៏មកដល់។

កៈ នៅពេលលោកតានៅក្មេង តើលោកតាចូលចិត្តធ្វើអ្វីដែរ ជាមួយបងរបស់លោកតា?

ខៈ មានតែធ្វើស្រែហ្នឹងទេ ដូចជាអត់មានអីផ្សេងក្រៅពីស្រែហ្នឹងផង គឺពួកយើងនៅខាងស្រែហ្នឹង។

កៈ ចុះលោកតាធ្លាប់លេងអីជាមួយហ្នឹងគាត់?

ខៈ មិនសូវជាបានលេងអ្វីចូលគ្នាផង មានតែបងប្អូន២នាក់ហ្នឹង។

កៈ នៅសព្វថ្ងៃ គាត់រស់នៅកន្លែងណាដែរលោកតា បងរបស់លោកតាណា? ហើយគាត់ធ្វើអ្វីដែរ?

ខៈ គាត់រស់នៅជប៉ុន ស្ទឹងចាស់។

កៈ ហើយគាត់ប្រកបមុខរបរអ្វីដែរ លោកតា?

ខៈ គាត់ជាអ្នកលក់ដូរបន្លែ លក់អីចឹងទៅ គាត់ធ្វើជាអនុភូមិសព្វថ្ងៃហ្នឹង។

កៈ ចុះតា នៅចាំម្ដាយរបស់លោកតាមានឈ្មោះអ្វីដែរទេ?

ខៈ គាត់មានឈ្មោះថា មីន តូច។

កៈ ចុះឪពុករបស់លោកតាវិញ?

ខៈ គាត់មានឈ្មោះថា ម៉ាក់ ហាន។

កៈ តើលោកតាមានចាំថា មកដល់បច្ចុប្បន្នពួកគាត់ទាំង២នាក់ មានអាយុប៉ុន្មានដែរ?

ខៈ មិនដឹងជាមានអាយុប៉ុន្មានហើយទេ ពីព្រោះអីអាយុច្រើនណាស់ដែរ
យូរហើយពួកគាត់ស្លាប់តាំងពីសម័យប៉ុលពតម្លេះ។ មិនដែលគិតអាយុគាត់ផង ហ្នឹងហើយ
នៅសព្វថ្ងៃប្រហែលជា៨០ឆ្នាំជាងហើយ ម្ដាយប្រហែលជា៩០ជាង ចង់ជិត១០០ឆ្នាំហើយក៏មិនដឹង
តាំងពីគាត់ខូចសម័យប៉ុលពតមកម្លេះ។

កៈ ចុះតាមានដឹងថាពួកគាត់ទាំង២នាក់ កើតនៅថ្ងៃណា ខែណា ឆ្នាំណា ហើយដឹងថា ភូមិអីដែលពួកគាត់កើតទេ?

ខៈ បានដឹងឪពុកកើតនៅស្រុកមោង ឃុំគៀរ។

កៈ ចុះខាងម្ដាយវិញ?

ខៈ ម្ដាយនៅខាងក្រឡាញ់ទឹកជារ ខាងខេត្តសៀមរាប។

កៈ អូ! នៅសៀមរាបវិញ។

ខៈ គាត់ជាអ្នកសៀមរាប។

កៈ ចុះលោកតា មានបានស្គាល់ដូចជាពួកគាត់កើតឆ្នាំអី នៅឆ្នាំខ្មែរ?

ខៈ អត់បានស្គាល់ទេ ស្គាល់មិនច្បាស់លាស់ ដឹងថាឪពុកនឹងឆ្នាំរោង ហើយតែម្ដាយមិនដឹងជាឆ្នាំអី បើគាត់នៅសម័យរឹករវ ប៉ុលពតហ្នឹង មនុស្សមិនសូវបានគិតគូររឿងឆ្នាំគ្នាអីផង ហើយក៏ទៅបួសទៅ។

កៈ ចុះតាមានដឹងថា ឪពុករបស់លោកតា គាត់ធ្វើអ្វីសំរាប់ចិញ្ចឹមជីវិតទេតា?

ខៈ គាត់ធ្វើស្រែ មុខរបរគាត់មិនលើសពីស្រែទេ កូនក៏ធ្វើស្រែ ឪពុកក៏ធ្វើស្រែហ្នឹង។ គាត់ធ្វើជាគណៈកម្មាធិការវត្តផង នៅសម័យនោះ កាលគាត់នៅសម័យសង្គមរាស្ត្រនិយម គាត់ធ្វើជាគណៈកម្មាធិការវត្ត។

កៈ ចុះតាស្គាល់អីគេខ្លះអំពីគាត់ ហើយគាត់ជាមនុស្សយ៉ាងម៉េចដែរតា?

ខៈ ទេ គាត់ដូចជាមនុស្សពីដើមគាត់លេងសើចខ្លះ ពិសារស្រាអីខ្លះទៅ លេល្បែងអី អាយុ៨៦ឆ្នាំគាត់ឈប់ពិសារស្រាទៅ ល្បែងក៏ដូចជាឈប់អីទៅ។ ចូលវត្តចូលវ៉ានឹងគេទៅ រក្សាសីលទៅ ដូចជាឈប់ប្រព្រឹត្តិអបាយមុខអីនឹងទៅ។

ក៖ ចុះគាត់ជាមនុស្សកាច ឬក៏ស្លូតដែរតា?

ខ៖ មិនជាកាចអីប៉ុន្មានទេ វាល្មមមនុស្សមិនកាចមិនស្លូត ស្រុកភូមិអីញាតិមិត្តគេរាប់អានច្រើន គាត់ស្រលាញ់រាប់អាន ហើយបើមនុស្សកាចគេមិនរាប់អានទេ។

ក៖ ចុះម្ដាយរបស់លោកតា តើគាត់ធ្វើអ្វីខ្លះ សំរាប់ចិញ្ចឹមជីវិតដែរតា?

ខ៖ ម្ដាយហ្នឹងក៏ដូចតែគ្នាដែរ ធ្វើស្រែដែរហ្នឹង។

ក៖ ធ្វើស្រែចំការដូចគ្នា ហើយគាត់ជាមនុស្សយ៉ាងម៉េចដែរតា?

ខ៖ មនុស្សគាត់ស្លូតតើ មនុស្សគាត់មិនសូវកាចអីទេ។

ក៖ ចុះលោកតាចាំឈ្មោះរបស់ជីដូនជីតារបស់តា ខាងម្ដាយដែរទេ?

ខ៖ ខាងម្ដាយឈ្មោះ ទឹម មិន ឪពុកហ្អា ហើយស្រីឪពុកឈ្មោះ យាយ ម៉ាប់ ហើយខាងឪពុកនឹងឈ្មោះ តាម៉ក់ ហើយម្ដាយនឹងឈ្មោះ យាយមន ហ្នឹង ឪពុកម្ដាយខាងឪពុក។

ក៖ ចុះតាដឹងថា គាត់កើតនៅឆ្នាំណា? ហើយកើតនៅពេលណាដែរ?

ខ៖ ហ្នឹងវាពិបាកដឹងចឹងហ្មងហាំ ពិបាកដូចជាមិនបានសួរគាត់ផង
ខ្ញុំគ្រាន់តែធំតិចទៅគាត់ខូចអស់បាត់ហើយ។ តានោះ កើតបែបមិនទាន់ផង ខ្មោចតាម៉ក់អីហ្នឹង
អត់ទាន់ដឹងហើយខ្មោចតាមិន ក៏អត់ទាន់ដែរ ទាន់តែខ្មោចយាយបង្កើត យាយម៉ាប់។
យាយខាងម្ដាយនឹងទាន់ ហើយយាយមន នឹងក៏កើតមិនទាន់ដែរ
ប៉ុនតែអត់ដឹងអាយុគាត់ពិតប្រាកដ។

ក៖ ចុះតាមានដឹងថា ដូចជាម្ដាយឪពុករបស់តាហ្នឹង គាត់ធ្លាប់បាននិយាយរឿងអីខ្លះ ទាក់ទងជាមួយជីដូនជីតាដែរទេ?

ខ៖ ហ្អេ គាត់មិនសូវបាននិយាយតែរឿងរ៉ាវនៅសម័យគាត់នៅក្មេងៗ
មកនឹងគាត់ទៅរកស៊ីស្រុកគេហ្នឹងទៅ ហើយបានម្ដាយខ្ញុំនឹងគាត់។ អាយុចាស់ណាស់ទៅហើយ

នឹងអាយុក៏ច្រើនណាស់ទៅហើយ ក្រមុំចាស់នឹង បានកូនតែ២ខែហ្នឹង
អស់ទោបានហើយគាត់មករស់នៅជាមួយយាយ យាយមន។

កៈ ចុះក្រុមគ្រួសារតា រស់នៅខេត្តនេះយូរនៅតា?

ខៈ នៅខេត្តនឹងរហូតខ្ញុំ ដែលខ្ញុំកើតមកដែរនឹង។

កៈ ប្រហែលជារយៈពេលប៉ុន្មានឆ្នាំដែរលោកតា?

ខៈ បើខ្ញុំវិញ រហូតបាត់ដំបងយើងនេះអត់មានប្រែប្រួលទៅណាទេ ហើយម្ដាយឪពុកដូចខ្ញុំប្រាប់ចឹង
កើតនៅស្រុកម៉ោង ខេត្តបាត់ដំបងដែរ ប៉ុន្តែម្ដាយនោះខាងកន្លែងទឹកជោរទៅណាស់ ប៉ិនបើខ្ញុំ
ចំពោះខ្ញុំផ្ទាល់កើតនៅបាត់ដំបង ស្រុកបាត់ដំបងនឹង។

កៈ ចុះតាមានសាច់ញាតិ ដែលគាត់រស់នៅក្រៅប្រទេស ក្រៅពីប្រទេសខ្មែរដែរទេតា?

ខៈ សាច់ញាត់មានតែសាច់ថ្លៃទេ ឯបងប្អូនបង្កើតដូចជាអត់មានទេ មានតែ២នាក់នឹង។

កៈ ចុះគាត់នៅឯណាដែរតា?

ខៈ អីណា បងប្អូន។

កៈ បងប្អូនតាដែលរស់នៅក្រៅប្រទេសណា?

ខៈ អូ! មានតែបងប្អូនជីដូនមួយអីមាន។

កៈ ចាស! គាត់រស់នៅប្រទេសអីដែរតា?

ខៈ នៅបារាំង នៅបារាំង។

កៈ តាបានទាក់ទងទៅកាន់ពួកគាត់ ដឹងពីសុខទុក្ខពួកគាត់ទេតា?

ខ៖ ហ្អេ! ពីដើមទាក់ទងបានប៉ុន្តែសព្វថ្ងៃ ដូចជាមិនដែរបានទាក់ទងមក មកផងនឹង ណ្ហើយចេះតែខ្លាចចិត្តថ្លើមគ្នា។ យើងឃើញគេនៅឯនោះ គេមានលុយកាក់ច្រើន ចេះទៅរាប់រកគេ បើគេរាប់រកយើង អាហ្នឹងយើងស្រួលទេ។ តែបើយើងទៅរាប់រកគេ គេថារ៉ាវរកលុយរកកាក់ អីក៏មិនដឹងគ្នាចឹង មិនសូបហ៊ានទេ បើហ៊ានអ្នកមកពីក្រៅមក មិនសូវហ៊ាន។ បើគេហៅ អាហ្នឹងទៅ តែបើថាគេមិនហៅអោយទោរកឯងៗ មិនហ៊ានចូលជិតទេ ព្រោះអ្នកខ្លះគេចោទយើងថា យើងទៅឃើញលុយកាក់អី គេមកពីឆ្ងាយក្រៅអីនឹងណា។

ក៖ ចុះភរិយារបស់លោកតា គាត់មានឈ្មោះអ្វីដែរតា?

ខ៖ គាត់មានឈ្មោះ ឆួន រឿយ។

ក៖ ហើយតាចាំពីពេលណា ដែរតាបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេ?

ខ៖ នៅឆ្នាំ១៩៧២។

ក៖ ថ្ងៃណាដែរតានៅចាំទេ? ថ្ងៃទីប៉ុន្មានដែរដឹងណាតា?

ខ៖ អត់ចាំទេ សម័យនោះវាមិនចាំច្បាស់លាស់ទេ សម័យនោះ សម័យសង្គ្រាមលុននុល ហើយនឹងណារៀបការនឹងខ្មែរក្រហម ហើយទាហានមកនៅព្រួញងប្រច្រាក់នឹង កញ្ជក់កន្ទៀតផងទេ។ បើនិយាយថាករនឹងមិនមែនការពេញមុខផងទេណា បានគ្រាន់តែបានការមែន ប៉ុន្តែការយើង អាក្នុងខាងខ្មែរក្រហមនៅក៏រឿងវាចង់ទាក់ទាញ គ្រួសារខ្ញុំអោយទៅខាងក្រៅដែរនឹងទេ វាមិនចង់អោយយើងការដែរនឹងណា។

ក៖ ចុះពេលដែលរៀបអាពាហ៍ពិពាហ៍ តាធ្វើដោយចិត្តឯង ឬម្ដាយឪពុកជាអ្នករៀបចំអោយតាដែរ?

ខ៖ ម្ដាយឪពុកឯណាមករៀបចំអោយនោះ អត់មានទេ។ អត់មានស្រលាញ់គ្នាអីមុនទេណា អត់ដឹងចិត្តគ្នាពីមុនអីមកទេ។ ស្រាប់តែឪពុកម្ដាយមើលឃើញក៏ត្រូវចិត្ត ត្រូវថ្លើមគ្នាទៅក៏ គូរវាចឹងហើយ មិនចាំស្រលាញ់ទេ ដល់ម៉ោងនេះទៅ វាចេះទំនោរទោរកគ្នាទៅវិញទៅមកចឹងណា។

ក៖ ចុះតាមានអោយជំនូនទៅកាន់យាយដែរទេ?

ខ៖ មានអោយដែរតើ។

ក៖ លោកតាអោយចំនួនប៉ុន្មានដែរ?

ខ៖ កាលនោះ ចំនួន៣០០០នេះណាប្រាក់ខាងណា៣០០០ជំនាន់នោះ វាមាសតំលៃ៣៥០ហើយ ៣៥០ចំនួន៣០០០ខ្មែរវាច្រើនដែរណា។

ក៖ ចុះតាមានអោយអីទៀតទោកាន់យាយទេ ដូចជាសង់ផ្ទះ ឬក៏អោយគោ អោយអីទៀតចឹងណា?

ខ៖ អត់ទេ កាលនោះអត់មានលុយសង់ផ្ទះអីទេ ខ្ញុំរត់សង្គ្រាមទេ យាយប្រពន្ធនឹងរត់មកពីព្រៃព្រៃ មកនៅភូមិព្រៃស្វាយនឹង មកនៅសុំផ្ទះគេនៅតើ។ ផ្ទះនៅឯព្រៃនោះគេអត់អោយទៅ សង្គ្រាមសូមផ្ទះគេការនិង កាលនោះបានកំសត់ដែរនឹងណា។

ក៖ ចុះតាអាចប្រាប់ថាពេលដែលតាបានជួបយាយ ដំបូងពេលណាដែរតា? ហើយមានរឿងរ៉ាវអ្វីដែរតាចង់ប្រាប់ ដូចជាហេតុអីបានជាតាស្រលាញ់យាយ ឬក៏អីចឹងណាតា?

ខ៖ បាទហ្នឹង! អារឿងនឹងដូចជាជួបដោយចៃដន្យទៅ វាមិនបានទៅទំនាក់ទំនងគ្នាដឹងចិត្ត ដឹងថ្លើមយូរផង។ ចុះបើរត់គ្នារត់ពីស្រែព្រៃមក មកនៅនឹងទោហើយចាស់ទុំក៏ឃើញ ហើយយើងក៏ស្រលាញ់ខ្លះដែរនឹងណា បើមិនស្រលាញ់ម៉េចយកធ្វើជាប្រពន្ធកើត។ អាហ្នឹងវាទាល់តែទំនោរចិត្តទៅវិញទៅមកខ្លះដែរ វាធ្លាប់ជាប្តីប្រពន្ធពីជាតិមិនមកដែរ ពេលឃើញគ្នាវាចេះតែ។

ក៖ ចុះតាចេះអាននឹងសរសេរភាសាខ្មែរបានល្អប៉ុណ្ណាដែរតា?

ខ៖ ទេ អក្សរខ្មែរចេះច្រើនដែរនឹងណា បើអក្សរបរទេសមិនចេះទេ បើនិយាយទៅមិនចេះ ចេះតែភាសាខ្មែរនឹង ព្រោះសិក្សាខាងផ្លូវលោកនឹងក៏បានតិច។ ហើយទៅបួសនឹង ទោបួសនឹងក៏មិនរៀនបាលី រៀនអីទេ រៀនតែធម្មៈអីខ្លះនឹង ធម្មៈព្រះធម៌វិន័យអីប៉ុណ្ណឹង អត់បានទៅរៀនភាសាបរទេសទេ។

ក៖ ចឹងភាសាដូចជាក្រៅពីភាសាខ្មែរ តាអត់ចេះភាសាណាមួយទេ?

ខ៖ មិនសូវចេះ មិនចេះបណ្ដោយបើនិយាយទៅ។

ក៖ វៀតណាម ថៃ អត់ចេះដែរលមើលទៅ។

ខ៖ អត់ចេះទេ ខ្មែរសុទ្ធណា។

ក៖ ចុះតារៀនថ្នាក់ទីប៉ុន្មានដែរតា?

ខ៖ ពីកាលដើមនោះ រៀនដល់ថ្នាក់តិចទេ ថ្នាក់ទី៩ពីសង្គមនោះ ហើយម្ដាយក្រល្ហេមល្ហាមណាស់ ចង់រៀនបានយូរដែរ ប៉ុន្តែម្ដាយក្រពេកគាត់ដើររហូត ដើរតែយំទេណា។ ដើរជំពាក់លុយគេបីបួនរយថាំងពីដើម ក្រមែនទែនហើយអោយកូនទៅរៀន ជួនណាអត់លុយក៏មានដែរ ជួនណាបានមួយរយ ពីររយ បួនប្រាំរយ ចឹងបានអាណិតគាត់។ សម័យដែលគាត់អត់ គាត់នៅជាមួយយើងទេ ដល់តែកូនរកស៊ីទៅបែបមិនមានអីទេ វាគ្រាន់ថាមានបាយទឹកណា។ ហើយរបស់របរអីល្អមប្រើបានខ្លះៗនឹង ក៏គាត់ស្លាប់ចោលយើង នឹងឃើញអាណិតគាត់ដែរ តែមិនដឹងធ្វើម៉េចទេ ការពារម៉េចបានអាយុជីវិតមនុស្សបាន។

ក៖ ចុះតាចាំថាសាលាណាដេតាបានរៀនដែរ?

ខ៖ សាលានៅព្រៃស្វាយនោះអី សាលានៅត្រង់ណាចេះ សាលានៅកៀនផ្ទះតាហ្នឹងឯងពីសង្គម។

ក៖ អូ! ចុះតាមានមិត្តភក្តិដែលតាធំធាត់មកជាមួយគ្នាទេតា?

ខ៖ អូ! មិត្តភក្តិ មិត្តភក្តិមិនសូវជាមានទេ។

ក៖ មិត្តភក្តិស្និទ្ធស្នាលចឹងណាតា?

ខ៖ មិត្តភក្តិស្និទ្ធស្នាលដូចជាមិនសូវមានទេ បើ។

ក៖ មិនសូវមាន មានន័យថាមានតែតា គាត់ឈ្មោះអីដែរលោកតា?

ខ៖ វាគ្រាន់តែជាមិត្ត មិត្តរៀនអីជាមួយគ្នាទេ កាលបួសអីនឹងមានខ្លះ ប៉ុន្តែអោយវាស្និទ្ធស្នាលទុកចិត្ត ទុកថ្លើមគ្នាដូចជាមិនមានទេ ព្រោះវាមិត្តភក្តិទាល់តែមនុស្សធ្លាប់ដើរលេង។
ចាប់មិត្តភក្តិពួកម៉ាក់អីច្រើនដូចតា មួយជីវិតដូចជាមិនសូវជាជួបទេ រឿងស៊ីផឹកលេងសើចអី ម្ល៉ោះហើយមិនសូវមានមិត្តភក្តិអីទេ។ ដឹងតែបានប្រពន្ធដឹងតែរកស៊ីធ្វើការ តែប៉ុណ្ណឹងឯង ពីកាលនោះបានប្រពន្ធថ្មីៗ មិនចេះដើរលេងផ្ទះគេឯង គិតតែខំធ្វើការ រកស៊ីទៅ។
ហើយមកដល់ចាស់នេះទៅ ឥលូវដើរ ចេះដើរ គេរកធ្វើអាចារ្យធ្វើអី ចេះតែជួយគែទៅចេះដើរទៅ។

ក៖ ចុះតាមានធ្លាប់ធ្វើការនៅវាលស្រែ ឬក៏ធ្លាប់ធ្វើស្រែអីទេតា?

ខ៖ ធ្លាប់តើ ធ្វើស្រែធ្លាប់រហូតមកទើបឈប់ប៉ុន្មានឆ្នាំនេះឯង ចាស់ខ្លួនហើយនឹងក៏ទុកអោយកូនចៅវាធ្វើទៅ តាធ្វើស្រែរហូតដល់មាន ផ្លាស់មុខរបរអីក្រៅនឹងអត់ទេ។

ក៖ ចុះតាដូចជាធ្លាប់ប្រកបអាជីវកម្ម លក្ខណៈគ្រួសារអីទេតា ដូចជាធ្លាប់លក់ដូរអីចឹងទៅណា?

ខ៖ អូ! សព្វថ្ងៃនេះ វាលក់តិចតួចហ្នឹងហើយ លក់មើលក់ចឹងៗអីតិចតួច ហើយកាល់ខ្មោចយាយហ្នឹងទៅ គាត់លក់តិចៗហ្នឹង។ មុខរបរគ្រាន់តែដោះស្រាយ មិនធ្វើមានធ្វើបានអីទេ គ្រាន់តែដោះស្រាយម្ហូបអាហារអីទិញប៉ុណ្ណឹងឯង មិនមានធំដុំអីដូចគេទេ។

ក៖ ចុះក្នុងជីវិតរបស់តា តាំងពីតូចរហូតដល់ធំណា តាធ្លាប់ធ្វើដូចជាធ្លាប់ធ្វើការអីខ្លះ សំរាប់រកកំរៃចិញ្ចឹមគ្រួសារ ឬកីចិញ្ចឹមជីវិតណាតា?

ខ៖ វាធ្លាប់អញ្ចេកនាឆ្នាំ យើងពីដើមមកធ្វើស្រែចឹង មកដល់ឆ្នាំ១៩៩៧ ក្រោយពីគេរំដោះប៉ុលពតមកនឹង ចាប់ផ្តើមអត់មាន អត់មែនទែនមានតែអង្ករ១០កំប៉ុងសុទ្ធ និងមាសកប់រាក់តែមួយហ៊ុនគ្មានផង។ ហើយមកនៅព្រៃស្វាយនឹង ចាប់ធ្វើស្រែខ្ចីរបស់របរគេនឹង ប្រើជាប់បិទស្រានឹងណា ហើយដាំបាយស្រាផង ស៊ីបាយជាមួយបាយស្រាហ្នឹងឯង អត់មានដាំបាយផ្សេងទេ។ គិតតែពីកំសត់នឹង ក្រនឹងវាជួបក្រមហាក្រនឹង ហើយវាស្គាល់ហើយ ប៉ុន្តែមានមិនទាន់ស្គាល់មាន បើក្រនឹងជួបហើយជួប មួយជីវិតនេះជួបច្រើនមែនទែន។

ក៖ ចុះមានការងារអីផ្សេងទៀតដែរតាបានធ្វើដែរទេ?

ខ៖ អូ! ការងារ ពីកាលយើងសម័យនោះ មានធ្វើខាងអង្គភាពភូមិអីគេដែរណា៎!
កាលសម័យនឹងក្រោយមកឈប់វិញទៅ ក្រោយមកកើតវត្តអារាមនៅកន្លែងនេះ
ចូលធ្វើអាចារ្យជាប់រហូតមកដល់សព្វថ្ងៃនឹង។

ក៖ ចុះតាពីក្មេងរហូតមកដល់ឥឡូវ តាឃើញជីវិតរបស់តាផ្លាស់ប្តូរអ្វីខ្លះ?

ខ៖ ទេ! វាមិនផ្លាស់ប្តូរអីច្រើនទេ បើផ្លាស់ប្តូរតែមនុស្សហ្នឹងឯង ពេលពូក្មេងមកវារូបស្អាត
ដល់សព្វថ្ងៃវាចាស់ទៅរូបចេះតែអន់ទៅៗ។ ហ្នឹងវាផ្លាស់ប្តូរណា ប៉ុន្តែជីវភាពអត់ចេះផ្លាស់បាន
ប៉ុន្តែពីដើមក្រមែនទែន ក្រល្ហេមល្ហាមមែនទែន។ កាលនោះ នៅជាមួយឪពុកម្តាយ
ប៉ុន្តែមកសព្វថ្ងៃចេះតែមានបាយហូបអីប៉ុណ្ណឹង
មិនមានអីច្រើនទេគ្រាន់តែមានបាយហូបនឹងគេប៉ុណ្ណឹងឯង។

ក៖ តែគ្រាន់ជាងពីមុន?

ខ៖ គ្រាន់ជាងពូមុនតិចបាទ។

ក៖ ចុះតាចូលចិត្តពិសាម្ហូបអីគេ ឬក៏ចូលចិត្តលេងល្បែងកំសាន្តអីគេខ្លះ ល្បែងប្រជាប្រិយអីចឹងណា?

ខ៖ មួយជាតិនេះដូចពិបាកអ្នកមិនចេះហូបស្រា ដូចពិបាកលេងនឹងគេដែរណឹងទេ។

ក៖ ដូចជាលេងឈូង លេងអី ទាញព្រ័ត្រលេងអីណាតា?

ខ៖ ពីដើមមានលេងអី មានលេងខ្លះដែរពីការនៅកំលោះណា
មានលេងឈូងលោតកន្ទាក់អីជាមួយគេ ជាមួយឯងខ្លះណា។ ចូលឆ្នាំ ចូលអីណឹងណា
ប៉ុន្តែដល់មានប្រពន្ធមក ដូចជាមិនដែលបានលេងសើចអីគេ រាំវ៉ៃកអីគេ
ចឹងបានជាស្តាយមកសម័យនេះ។ គេកើតអាបាសពេញទឹកពេញដី ឯងនេះអត់រាំអីហ្នឹងគេ
គេកើតពេញទឹកពេញដីពេញនគរ គេផ្សាយស្រាឯងអត់ចេះផឹកស្រា។ ចឹងបានអភ័ព្វដែរណឹង
តែតាចេះតែស្តាយដែលហ្នឹង មិនដឹងធ្វើម៉េចវាដំណើរជីវិតទៅហើយ យើងត្រូវតែរកសេចក្តីល្អច្រើន។
ទុកអោយក្មេងៗវាធ្វើទៅ យើងចាស់ហើយយើងរកតែបុណ្យកុសល្យសន្សំផល
ទៅខាងមុខប៉ុណ្ណឹងឯងចៅ។

កៈ ចុះតាចូលចិត្តិសារម្ហូបអីជាងគេ?

ខៈ អីយ៉ា! ម្ហូបណឹង។

កៈ ម្ហូបមួយមុខ ឬពីរមុខដែលតាចូលចិត្តពិសារជាងគេ ចឹងណា?

ខៈ បើសព្វថ្ងៃនឹង បើនិយាយពីដល់ទៅ ជូនណាដាក់បួនប្រាំមុខហ្មង សុទ្ធតែត្រូវប្រហុក
ទឹកគ្រឿងអីចូលចិត្តវិញ បន្លែអីវិញ ដល់សាច់គោសាច់ជ្រូកអត់លូកមួយម៉ាត
ក៏មានដែលហ្នឹងចូលចិត្តចឹងមកដល់ចាស់តិចណា។

កៈ ចុះលោកតាចូលចិត្ត ដូចជាតាចងចាំចំរៀងអី តាំងពីក្មេងដែលតាបានរៀនរហូតដល់ឥលូវណា?

ខៈ អារឿងចំរៀងនឹងដូច ដូចមិនមានឱុងតែម្តងចៅ មិនសូវជាចាប់អារម្មណ៍ចំរៀងអីច្រៀងទេ។

កៈ តែលោកតាចូលចិត្តស្តាប់ចំរៀងណាដែរ?

ខៈ ស្តាប់ពីដើម ស្តាប់ខ្លះដែរពីក្មេងណា បើសិនស៊ីន ស៊ីសាមុតអី, រស់ សេរីសុទ្ធាអី, ប៉ែន រ៉នអី, ហួយ
មាស,ចេះស្តាប់ខ្លះ។ ប៉ុន្តែមកដល់សម័យនេះ ដូចជាមិនមានអារម្មណ៍ មិនពិរោះណា
ហ្នឹងយើងមនុស្សចាស់ចឹងឯង មិនដូចក្មេងៗទេណា សម័យគេសព្វថ្ងៃគេបទភ្លេងគេទំនើបៗ។

កៈ ចុះតានៅក្នុងក្រុមគ្រួសាររបស់លោកតា មានអ្នកចេះលេងឧបករណ៍តន្ត្រីអីទេតា?
ដូចបងប្អូនអីចឹងណាតា?

ខៈ ដូចមិនមាន អត់មានៗ។

កៈ អត់មានទាំងអស់ហ្មង ចុះផ្ទះរបស់តាមានលក្ខណៈយ៉ងម៉េចដែរ
តាំងងពីក្មេងរហូតមកដល់ឥលូវណាតា?

ខៈ ពីដើមផ្ទះតូចៗ ទើបលើកផ្ទះបានប៉ុណ្ណឹងទេ ពីឆ្នាំ១៩៩៥ ដំណាលគ្នានឹងកើតវត្តព្រៃស្វាយនេះឯង
ដែលការកូនៗដំបូងណា ចាប់លើកផ្ទះទើបបានប៉ុណ្ណឹង ពិដើមផ្ទះតូចបើក្រ មនុស្សក្រ
ដែលទៅធ្វើផ្ទះអីបានដូចគេទេ។

កះ ចុះអ្នកណាជាអ្នកសាងសង់ ឬក៏មានអ្នកណាជួយសាងសង់ ឬក៏តាសាងសង់ផ្ទះដោយខ្លួនឯង?

ខះ តាជួលគេអោយមកធ្វើតើ ជួលគេទេ។

កះ ជួលគេ ដើម្បីសាងសង់ណាតា។ មានសំភារៈអីគែខ្លះ ដែលតាបានសាងសង់ផ្ទះហ្នឹងណា?

ខះ គ្មានសំភារៈអីទេ មានតែឈើព្រៃអី ទិញគេទាំងអស់នឹង ឈើទាំងអស់នឹងហើយជួលជាង
ហើយឧបករណ៍ធ្វើផ្ទះនឹងគឺខាងគេ អ្នកជាងនឹងហើយ គេជាអ្នកស៊ីឈ្នួលយើង។

កះ ចុះនៅក្នុងក្រុមគ្រួសាររបស់តា មានអ្នកណាគេគាត់ចេះសាងសង់ផ្ទះដែរទេតា?

ខះ មិនមានទេ សុទ្ធតែកូនស្រីទាំងអស់ហ្នឹង។

កះ ចាស! លោកតាក៏ចេះដែរ?

ខះ អត់សូវចេះដែល បើចេះដែលចេះខ្លះ ប៉ុន្តែចេះមិនច្បាស់ និងធ្វើបានខ្លះ។

កះ លោកតាចេះតាំងពីពេលណាដែរ?

ខះ ចេះហ្នឹង កាលនៅបួសជួយធ្វើវត្តអារាមអីទៅ ចេះទេបានជួយធ្វើទៅ ចេះធ្វើខ្លះៗចឹងណា។

កះ ចុះតាមានជំនាញ់អីដែលតាបានបន្ត វេនពីគ្រួសាររបស់តា ឬក៏ម្ដាយឪពុកតាបានបង្រៀនតា
ចឹងណាដូចជា វេញវ័ល្លិ ឬក៏កូរស្ករ ឬក៏ធ្វើអីមួយដែលតាចេះពីពួកគាត់ចឹងដែរទេ?

ខះ ទេ ដូចជាជំនាញ់ដូចតា បានប្រាប់មិនហើយ ជំនាញ់មិនលើសពីធ្វើស្រែ
ធ្វើស្រែជាជំនាញ់មួយជីវិត គឺស្រែនឹងជាអាជីពប្រចាំជីវិត និងបណ្ដោយវាអត់។

កះ ចុះតាអាចប្រាប់ខ្ញុំបានទេ ដូចជាអំពីជីវិតរបស់តាលំបាកម៉េចគេខ្លះ ចឹងណាលោកតា?
ហើយនៅពេលដែលលោកតាលំបាកហ្នឹង តើតាឆ្លងកាត់ការពិបាករបស់តាហ្នឹង
ដោយរបៀបណាចឹងណាតា?

ខ៖ ចឹងបានដូចជាខ្ញុំប្រាប់រួចហើយ ថាពីដើមពីតូចមកឪពុកម្តាយក្រណាស់
ល្វេមល្វាមដល់មកធំតិចមក បានអោយសិក្សានោះក៏បានច្រើនដែរ
សិក្សាព្រោះម្តាយក្រចង់អោយកូនរៀន មានកង់ណាជិះនឹងគេ។
នៅតែនេះនឹងរកប្រាក់អោយកូនមួយថ្ងៃ ១០០ ទៅ ២០០ សឹងមិនបានផងនឹង ឈប់ទៅៗ
ដើអាយុ១៨ឆ្នាំ ធ្វើស្រែជាមួយឪពុក។ ១៨ឆ្នាំទៅបួសបានសឹកពីបួសមកវិញនឹងបាន១ឆ្នាំ ២ឆ្នាំ
នឹងក៏ដណ្តឹងយកប្រពន្ធហ្នឹងទៅណា។ ហើយាវាមិនមានទេ ក្រល្វេមល្វាមលំបាក
ប៉ុន្តែការតស៊ូក្នុងឆាកជីវិត វាអត់បួររហូតមកដល់សព្វថ្ងៃ ជិតសម័យប៉ុលពតនឹង
រងទុក្ខវេទនាខ្លាំងមែនទែននៅសម័យនោះ។ ហើយអ្នកណាដែលឆ្លងកាត់សម័យប៉ុលពត
និហាយើងដឹងហើយសឹងថាមិនបានជីវិតរស់ផង។ នៅក្នុងសម័យនោះ
ប៉ុន្តែបុណ្យកុសល្យយើងមានវាចេះតែឆ្លងកាត់ អោយផុតសម៧យប៉ុលពតទៅណា
នៅសម័យនោះតាក្បត់ជាងគេមួយសម័យប៉ុលពតហ្នឹង។ បងប្អូនគេរត់ទៅក្រៅណា
ហើយគេរត់ចូលមកវិញ រត់ចូលមកវិញគេយកចុងកាំភ្លើងអី សម៧យសង្គ្រាមណា
ភ្លើងសង្គ្រាមប៉ុលពតហ្នឹងណា ឆ្នាំ៧៦នឹង ឆ្នាំ៧៥ហ្នឹង ប៉ុលពតចូលកាន់ក្តាប់ឆ្នាំ៧៦ កាន់ក្តាប់៧៧
រហូតមកដល់ឆ្នាំ៧៩ហ្នឹង។ ឆ្នាំ៧៦ហ្នឹងបងប្អូនមក យកកាំភ្លើងមកសង្ងំនីនឹង
ហើយវាចូលមកដល់ហើយសម័យនោះខ្មែរក្រហម សម័យប៉ុលពតគ្រាន់តែបាក់ស្លាបព្រាមួយ
ក៏ខ្លាំងដែណាថៅ។ ពេលដែលតាយកបាយមកដល់ យកបាយអោយពួកនោះស៊ី
បើយើងមិនយកអោយស៊ីម៉េចបាន គ្នាភ័យខ្លាចដែលហ្នឹង និយាយពីភ័យដល់ហើយដល់គេចេញ។
ទៅវិញអស់នឹកឃើញទៅគេចាក់សំលាប់ចោលនៅសម័យនោះ តែគេដឹងថាមានរឿងមិនល្អ
គេចាប់មិនទុកយើងទេ ស្រួលមិនស្រួលគេផ្តាច់ទាំងពូជទៀត។
មិនមែនសំលាប់តែម្នាក់ទេសម័យប៉ុលពតហ្នឹង ថៅកើតមិនទាន់ប៉ុន្តែតាកើតទាន់ដឹងណាស់
បានពូជណាដែលមិនល្អគេមិនទុក អោយសត្រូវជាមួយគេទេណា។ សម័យប៉ុលពតហ្នឹង
តាមានរឿងនឹងគួរអោយខ្លោចចិត្ត កាលសម័យនោះ នឹកឃើញថាងាប់ហើយគ្មានរស់ទេ
ប៉ុន្តែគុណបុណ្យដែលយើងគ្មានកម្មពារ ជាមួយរឿងគេសំលាប់ហ្នឹងណា។
យើងមិនដែលសំលាប់គេនឹងបានជាគេមិនសំលាប់យើង
ដល់រួចមកបានរួចសម័យប៉ុលពតមកគេឆ្នាំ៧៩ និងមករហូតទៅកំសត់ណាស់ ដើរពីនេះទៅស្រុកថៃ
រែកអង្ករយកមកអោយប្រពន្ធនៅផ្ទះនោះ។ ហើយកាលណាកូនស្លាប់អស់ អត់មានសល់មួយទេ
កូនបាននៅតែ២នាក់ប្តីប្រពន្ធ ដូចលលកញីឈ្មោលចឹង មើលទៅកំសត់ណាស់
បើនិយាយពីកំសត់វិញសឹងតែថារៀបរាប់។ ចឹងបានថាដល់ប្រពន្ធស្លាប់ចោល
នឹកឃើញអនុស្សាវរីយ៍ដែលយើង ធ្លាប់បានកំសត់ជាមួយគ្នាណា
វាចេះតែកណ្តោចកណ្តែងរហូតមួយឆ្នាំជាងហើយ នៅតែនឹកស្រណោះអាលោះអាល័យគ្នា។

ហើយប្តីប្រពន្ធ វាមិនដែលទាស់ទែងខ្វែងគំនិតគ្នាអីផង ដឹងចិត្តគ្នាស្រលាញ់គ្នាទៅវិញទោមក ប៉ុន្តែយើងដល់បែកគ្នាទៅ មានអនុស្សាវរីយ៍ល្អដែលនៅក្នុងគ្រួសារ។

ក៖ ចុះតាឆ្លងកាត់ពេលវេលាពិបាកទាំងអស់ហ្នឹង ដោយរបៀបណាដែរតា? ដូចជាតាធ្វើអីមួយ ឬគិតម៉េចដើម្បីឆ្លងកាត់ចឹងណា?

ខ៖ ចេះតែខំធ្វើការរកស៊ី ដូចតាប្រាប់ចឹងឆ្នាំ៧៩មកអីសោះ និងធ្វើស្រាហើយលីអូសលីស្មាទៀត ហើយចំងាយ មួយគីឡូ ពីរគីឡូ ហើយរែកស្រាយកទោលក់ដោយខ្លួនងទៀត។ ហើយប្រពន្ធនៅផ្ទះបិទស្រាទៅ ទៅលក់ចំងាយ ប្រាំមួយ ទៅប្រាំពីរគីឡូហ្នឹង រែកស្រាយកទៅលក់ឡើងផ្លែនៅលើស្មាទៀត រែកស្រាយកទៅលក់ទំរាំបានទៅទិញជ្រូកយូរៗ ចិញ្ចឹមបានតិចទៀតទៅទិញគោ ទៅទិញក្របីបានកំរើបៗតិចមក។ បានស្មើនឹងគេអ្នកស្រុកអ្នកភូមិនឹងគ្រាន់ថា បានរស់នៅជាមួយគេ មិនបានលើសគេទេប៉ុន្តែថាប្រហែលជាគេអ្នកល្មមៗ គ្រាន់តែបានតែប៉ុណ្ណឹងឯង។ ចំពោះគេអ្នកមាន យើងតាមគេមិនទាន់ទេ ព្រោះបុណ្យគេច្រើនតាមគេម៉េចបាន បានតែម៉ារស់ៗសព្វថ្ងៃនឹង មិនអត់ល្ហេមល្ហាមពេកទេ។

ក៖ ចេះតែស៊ូទ្រាំទៅណាលោកតា។

ខ៖ ស៊ូទ្រាំបានតែប៉ុណ្ណឹងទេ។

ក៖ ចុះតាពេលណា ដែលតាគិតថាជាពេលវេលាដែលសប្បាយ បំផុតនៅក្នុងជីវិតបរស់តាចឹងណា?

ខ៖ ពេលដែលសប្បាយ ដែលតាសព្វថ្ងៃហ្នឹងឃើញតែមួយមុខទេ នឹកឃើញថាតាចូលវត្តបានធ្វើសេចក្តីល្អ បានធ្វើបុណ្យសន្សំកុសល្យ សំរាប់យកផលទោកាន់ជាតិខាងមុខ។ នឹកឃើញល្អពេលនឹងឯង សប្បាយចិត្តនៅពេលនឹង រីករាយនៅពេលនឹង ពេលនាបានធ្វើបុណ្យម្តងៗ ថ្ងៃមុនបានធ្វើបុណ្យ ធ្វើបុណ្យធំហ្នឹងណា ៥០, ៦០តុមនុស្សរាប់រយ ប្រាំ, ប្រាំមួយនាក់សប្បាយ ដើរក៏សប្បាយអោយតែនឹកឃើញ ពេលណាសប្បាយពេលហ្នឹង ស្រលាញ់សេចក្តីល្អ និងសប្បាយច្រើនសំរាប់ជីវិតហ្នឹង។

ក៖ មានអីទៀតទេតា?

ខ៖ ដូចជាមិនមានអីទៀតទេប៉ុណ្ណឹងឯង ប៉ុន្តែក្នុងជីវិតនឹងស្រលាញ់ដូចជាខ្ញុំថាតែប៉ុណ្ណឹង ចង់តែបានល្អ ហើយចង់បានមិត្តភក្តិនឹងអោយបានជុំទាំងអស់គ្នា ក្នុងស្រុកក្នុងភូមិ។ ក្នុងចិត្តតានឹងវាខុសគេ ខង់អោយបានមិត្តភក្តិអោយបានញាតិមិត្តច្រើន ក្នុងស្រុកក្នុងភូមិនឹង មានបញ្ហាមិនចង់អោយបាត់ញាតិជិតខាង គេមិនរាប់រកគេស្អប់យើងទេ ចង់អោយគេថាគេស្រលាញ់យើងរាប់អានយើង ដើម្បីសេចក្តីសុខដល់ក្រុមគ្រួសារយើង តែប៉ុណ្ណឹងទេសព្វថ្ងៃនេះ។

ក៖ ចុះតានៅក្មេងនឹង តាមានក្តីស្រមៃអី ពេលដែលតាធំឡើងចង់ធ្វើទេតា?

ខ៖ កាលនោះដូចជាមិននឹកឃើញចង់ស្អីផង ព្រោះយើងមានកំរិតវិជ្ជានឹងវា យើងបានរៀននាំទាបចំណេះចេះដឹងខ្សោយ ហើយយើងចង់ធ្វើការងារអីធំ ក៏ធ្វើទៅមិនកើតដែរ បើយើងរៀនចេះតិចតួចហ្នឹង វាមនាដូចតាធ្លាប់ថា វាមានតែមុខរបរស្រែនឹងឯងដែលច្រើនធំជាងគេ។

ក៖ គ្រាន់តែចង់ធ្វើជាកសិករ ហើយមានចំណេះចេះដឹងខ្លះដឹងណាតា?

ខ៖ ហ្នឹងហើយ។

ក៖ ចុះតា បើសិនជាអាចផ្តាំអ្វីទៅកាន់កូនចៅជំនាន់ក្រោយៗទៀត តានឹងនិយាយអ្វីគេខ្លះទៀត ទៅកាន់ពួកគាត់ចឹងណាតា?

ខ៖ ខ្ញុំចង់ណែនាំថា ក្មេងៗជំនាន់ក្រោយយុវជនយុវនារី កុមារាកុមារីជំនាន់ក្រោយនឹង ចង់អោយថាយើងរស់នៅក្នុងសង្គម បានស្រុកភូមិក្នុងប្រទេសនឹង ធ្វើយ៉ាងណាធ្វើខ្លួនអោយល្អ បានជៀសវាងជាពិសេសថ្នាំញៀន និងសព្វថ្ងៃនឹងពេញទឹកពេញដីហើយ។ ស្រុកយើងបានចង់អោយក្មេងៗ ជៀសវាងហ្នឹងដើម្បីរក្សាជីវិតនឹងអោយបានគង់វង្ស ល្អអោយបានសុខបានចំរើនហ្នឹង បើជៀសវាងបាននឹងយើងបានសុខបានចំរើន។ បើសិនជាយើងមិនជៀសវាងបានទេ ភ័យព្រួយទៅណា ភ័យព្រួយនឹកឃើញគញនាមិនដឹងយ៉ាងណា បើវាជ្រុលជ្រួសទៅលើជក់ថ្នាំអីហ្នឹង អនាគតទៅជីវិតនឹងក្រែងបែកថ្នាំទៅ បាត់បង់សតិបញ្ញាស្មារតីទៅ ឆ្កួតវង្វេងទៅចប់ហើយជីវិតនឹង មនុស្សយើងតាបាត់ស្មារតីហើយ រកស៊ីអីក៏លែងកើតដែរ។ គ្រាន់តែមានបញ្ញាស្មារតីប៉ុណ្ណឹងផង យើងដោះស្រាយបញ្ហាជីវិតមិនចង់បានផង សឹងតែមិនកើតហើយ ចុះវាបាត់បង់សតិហើយ ហើយតាសព្វថ្ងៃមានអាយុចំណាស់នេះ ចង់អោយតែវាកុំអោយប្រព្រឹត្តអបាយមុខប៉ុណ្ណឹងឯង។

កៈ ចុះលោកតាមានអីទៀត ចង់ផ្តាំផ្ញើរអីទេតា?

ខៈ ហ្នឹងហើយ ផ្តាំផ្ញើរតែប៉ុណ្ណឹងថាអោយក្មេងៗនៅជំនាន់ក្រោយ
ធ្វើយ៉ាងណាធ្វើជីវិតហ្នឹងអោយបានសុខ បានចំរើន ជៀសវាងអបាយមុខ មានស្រីស្រាល្បែងស៊ីសង
សេពគប់មនុស្សអាក្រក់ជាមិត្តអីហ្នឹ គឺយើជៀសវាងអោយបាន។ បើយើងចេះសេពគប់
សេពគប់មនុស្សល្អៗ ដែលដឹកនាំជីវិតយើងទៅរកការរីកចំរើន កុំអោយសេពគប់មិនល្អ
វានាំអោយយើងវិនាសអន្តរាយជីវិត តាចង់ផ្តាំតែប៉ុណ្ណឹងឯង។

កៈ ចាស! ចឹងអរគុណតាសំរាប់ការសំភាសន៍នៅថ្ងៃនេះ និងការផ្តល់ប្រវត្តិរបស់លោកតាចឹងណា៕